**គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ**

**REPUBLICAN DEMOCRACY PARTY**

# គោលនយោបាយសំខាន់ៗរបស់ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ

## នយោបាយក្នុងប្រទេស

### ១- អនុវត្តច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

គណបក្សគោរពរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ប្រទេសអោយបានពេញលេញ ដោយមិនអនុញ្ញាតិអោយជនណារំលោភច្បាប់ដាច់ខាត។ ជនគ្រប់រូបត្រូវស្ថិតនៅតាមច្បាប់របស់រដ្ឋ អ្នកបំពានត្រូវមានទោស។

### ២- ផ្តល់សិទ្ធិ និងសេរីភាពប្រជាពលរដ្ឋខ្មែរ

ប្រគល់សិទ្ធិអំណាចបរិបូរណ៍ បញ្ចេញមតិដោយសេរីតាមបែបប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងសេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្ស។ មានសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី ដោយគ្រាន់តែជូនដំណឹងដល់អាជ្ញាធរពាក់ព័ន្ធ។ បើកសិទ្ធិសេរីភាពក្នុងការសរសេរ ផ្សាយព័ត៌មានតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មានដោយសេរី និងបើកអោយឯកជនមានសិទ្ធិកាន់កាប់ស្ថានីយ៍វិទ្យុ និងទូរទស្សន៍។

### ៣- អនុវត្តប្រព័ន្ធឯកត្តនាម ក្នុងការបោះឆ្នោតជ្រើសតាំងមេដឹកនាំ

សភាតំណាងរាស្ត្រ ព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី បើកអោយមានបេក្ខជនឯកត្តនាម។ មេដឹកនាំខេត្ត ស្រុក (ខណ្ឌ) ឃុំ (សង្កាត់) និងភូមិត្រូវបោះឆ្នោតដោយប្រជាពលរដ្ឋ។ ត្រូវកែប្រែប្រព័ន្ធសមាមាត្រ ដែលមានការតែងតាំងពីគណបក្ស តាមរបៀបផ្តាច់ការនិយម គ្រួសារនិយម និងបក្សពួកនិយម។ តំណែងនាយករដ្ឋមន្ត្រីត្រូវបានកំណត់ត្រឹមពីរអាណត្តិប៉ុណ្ណោះ។

### ៤- កំណែទម្រង់ប្រព័ន្ធរដ្ឋាភិបាល

**គ.ស.រ.ប** នឹងធ្វើការកាត់បន្ថយ និងឈានលុបបំបាត់អំពើពុករលួយអោយអស់ ដាក់ទោសទាំងអ្នកស៊ីសំណូក និងអ្នកសូកប៉ាន់ ដោយបង្កើតច្បាប់ប្រឆាំងអំពើរពុករលួយស្របតាមបទដ្ឋានអន្តរជាតិ។

អនុវត្តន៍យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍បែងចែកអំណាចធំៗ ទាំងបី រីដាច់ពីគ្នា គឺ អំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ អោយច្បាស់លាស់ ដើម្បីអោយមានតុល្យភាពអំណាច។ មន្ត្រីរាជការ ទាហាន ប៉ូលីស មិនត្រូវអោយមានមុខងារពីរ រីការងារស៊ីវិលផង និងជាកងកំលាំងប្រដាប់អាវុធផងទេ។ ក្នុងអំណាចនីតិប្រតិបត្តិ ដូចជា ធ្វើរដ្ឋមន្ត្រីផង និងជាតំណាងរាស្ត្រ ឬកិច្ចការតុលាការទៀត។ កែប្រែប្រព័ន្ធតុលាការធ្វើជាឧបករណ៍បំរើអោយមាននយោបាយរបស់ខ្លួន។

ធ្វើអោយប្រសើរឡើងនូវលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន តាមរយៈធ្វើកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (វិមជ្ឈិការ និងសហវិមជ្ឈិការ) ដើម្បីបង្កើនប្រតិបត្តិមុខងារ និងសេវាកម្មរបស់ជាតិ ដោយរដ្ឋាភិបាលធ្វើប្រតិភូកម្មអំណាច

ឬភារកិច្ចជាក់លាក់ណាមួយអោយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអ្នកនៅជិតប្រជាពលរដ្ឋ ក្នុងការបំរើសេវាកម្មទាំងនោះជូនប្រជាពលរដ្ឋអោយបានទាន់ពេលវេលា។

បន្ថយចំនួនមន្ត្រីដែលមិនចាំបាច់ ដើម្បីកាត់បន្ថយចំណាយ និងដំឡើងប្រាក់ខែជូនមន្ត្រីរាជការប៉ូលីស ទាហាន អោយបានសមស្របទៅតាមតួនាទី និងមុខងារ។ គ.ស.រ.ប សន្យានឹងបង្កើនប្រាក់បៀវត្ស ដល់មន្ត្រីរាជការ ប៉ូលីស ទាហាន អោយបាន ២០%រៀងរាល់ឆ្នាំ នៃការកាន់អំណាចរបស់ខ្លួន។

ប្រាក់បៀវត្សរបស់សភាតំណាងរាស្ត្រ និងព្រឹទ្ធសភា នឹងត្រូវកាត់បន្ថយ ៣៥% នៃប្រាក់បៀវត្សសព្វថ្ងៃ។ រដ្ឋាភិបាលធ្វើការបំរើអោយផលប្រយោជន៍របស់ប្រទេស មិនមែនធ្វើការបំរើអោយផលប្រយោជន៍បក្សពួក និងគណបក្សទេ។ រដ្ឋាភិបាលដែលបង្កើតឡើង ដោយប្រជាពលរដ្ឋ បំរើប្រជាពលរដ្ឋ និងជារបស់ប្រជាពលរដ្ឋ ។

**៥- លើកស្ទួយវិស័យការពារជាតិ និងសន្តិសុខ**

កងទ័ព ប៉ូលីស និងកងកំលាំងសន្តិសុខជាតិទាំងអស់ ជារបស់ប្រជាពលរដ្ឋ ហើយប្រដាប់ដោយអាវុធទំនើប មានប្រាក់ខែសមរម្យ និងទៀងទាត់ កងទ័ព និងប៉ូលីស មិនលំអៀងទៅគណបក្សនយោបាយណាមួយទេ មានតួនាទីការពារជាតិ ការពារទឹកដី ការពារសន្តិសុខជូនប្រជាពលរដ្ឋ ការពាររដ្ឋធម្មនុញ្ញ និងជួយកសាងប្រទេស ជួយសង្គ្រោះប្រជាពលរដ្ឋ នៅពេលមានគ្រោះអាសន្នធម្មជាតិ និងមហន្តរាយផ្សេងៗ ត្រូវមានគោលនយោបាយ ធានារ៉ាប់រងជីវិតទាហាន ប៉ូលីស និងកងកំលាំងសន្តិសុខជាតិ ដែលរងគ្រោះថ្នាក់ដល់ជិវិត ក្នុងបេសកកម្ម ការងារការពារជាតិ មាតុភូមិ ដោយត្រូវផ្តល់ជូនដល់គ្រួសារ នៃទាហាន និងប៉ូលីស កងការពារសន្តិសុខ ជាតិពលីជីវិតយុទ្ធជនពិការ ក្នុងពេលធ្វើបេសកកម្ម នឹងត្រូវបានយកចិត្តទុកដាក់ លើកទឹកចិត្តអោយមាន ការរស់នៅសមរម្យ។ ប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលមានអាយុ ១៨ឡើងទៅ ត្រូវមានកាតព្វកិច្ចចូលបំរើកងទ័ពដោយស្ម័គ្រចិត្តរយៈពេល ០២ឆ្នាំ។ បន្ទាប់ពីរយៈពេល ០២ឆ្នាំនោះមក រដ្ឋត្រូវផ្តល់តណទាន ដើម្បីរៀនសូត្របន្តរ ឬរៀនមុខជំនាញអ្វីមួយ។ ប៉ូលីសទាំងអស់ត្រូវរើសចេញពីកងទ័ព ដែលមានការហាត់រៀនបាន ត្រឹមត្រូវតាមក្បួនខ្នាត ឬអ្នកដែលចេះច្បាប់ក្បួន មានជំនាញគ្រប់គ្រាន់។

**៦- អភិវឌ្ឍទូរគមនាគមន៍ និងទេសចរណ៍**

កសាងប្រព័ន្ធគមនាគមន៍ ផ្លូវទឹក ផ្លូវដែក ផ្លូវអាកាស និងទូរគមនាគមន៍អោយបានល្អប្រសើរ ដើម្បីសំរួល ដល់ការទំនាក់ទំនង និងការធ្វើដំណើររបស់ប្រជាពលរដ្ឋ។ រៀបចំតំបន់ទេសចរណ៍អោយល្អបំផុត ដោយយកតំបន់ អង្គរវត្តអោយរដ្ឋកាន់កាប់ ហើយប្រាក់ចំណូល ២៥% សំរាប់ជូនប្រជាពលរដ្ឋនៅខេត្តសៀមរាប ដើម្បីលើកទឹក ចិត្តពួកគេ ក្នុងការថែរក្សាបរិស្ថានអង្គរអោយបានគង់វង្សល្អ និងចំណូល ៧៥%ទៀតបង់ ចូលថវិការជាតិ។ ចំណែក ផ្លូវជាតិលេខ៤ មិនត្រូវអនុញ្ញាតិអោយក្រុមហ៊ុនឯកជនកាន់កាប់ ឬធ្វើអាជីវកម្មបានឡើយ។ ធានា និងការពារ សន្តិសុខ និងសុវត្ថិភាពជូនអ្នកទេសចរណ៍គ្រប់ប្រភេទ អោយបានល្អប្រសើរ ដើម្បីទាក់ទាញអោយមានភ្ញៀវ ទេសចរណ៍ចូលប្រទេសយើងបានច្រើន បង្កើនចំណូលថវិការជាតិ។ **គ.ស.រ.ប** នឹងស្វែងរកប្រាក់កម្ចី ឬជំនួយ អន្តរជាតិ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងផ្លូវតាមព្រំដែន ឡាវ ថៃ និងវៀតណាម ក្នុងអាណត្តិទី១ នៃការជាប់ឆ្នោតចូលកាន់ដំណែងរបស់ខ្លួន។

**៧- ដំណោះស្រាយជនអន្តោប្រវេសន៍ខុសច្បាប់**

ធ្វើច្បាប់អន្តោប្រវេសន៍ខុសច្បាប់ ជនភៀសខ្លួនដែលអាចចូលសញ្ជាតិខ្មែរ ត្រូវគោរពច្បាប់រដ្ឋ ចេះអាន ចេះសរសេរ ចេះប្រវត្តិសាស្ត្រខ្មែរ។ បែងចែកច្បាស់លាស់រវាងជនភៀសខ្លួន និងជនអន្តោប្រវេសន៍។ ការចូលរួម

សញ្ជាតិត្រូវប្រឡង និងសំភាសន៍ជាផ្លូវការ ដោយមន្ត្រីអន្តោប្រវេសន៍ អ្នកប្រឡងជាប់ត្រូវទទួលបានវិញ្ញាបនប័ត្រផ្តល់សិទ្ធិ និងកិត្តិយស។

បង្កើតអោយមានជនភៀសខ្លួនតាមព្រំដែន ក្នុងករណីចាំបាច់ ដោយសហការជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន និងស្ថាប័នដែលពាក់ព័ន្ធ។ ជនភៀសខ្លួន និងអន្តោប្រវេសន៍ទាំងអស់អាចមានការជ្រើសរើសវាសនាខ្លួនក្នុងករណី ៣យ៉ាង:

1- ជនភៀសខ្លួនអាចទៅទីលំនៅថ្មី នៅប្រទេសទីបី ប្រសិនបើមានការយល់ព្រមគ្នារវាងភាគីទាំងដែលពាក់ព័ន្ធ។
2- ជនភៀសខ្លួនអាចវិលទៅកាន់មាតុប្រទេសខ្លួនវិញ ដោយស្ម័គ្រចិត្ត យោងតាមសន្ធិសញ្ញាក្រុងប៉ារីសដែលត្រូវចុះហត្ថលេខាដោយប្រទេសចំនួន ១៩ ដែលមានប្រទេសវៀតណាម ជាប្រទេសសហលេខាទីមួយផងដែរ។
3- អាចសុំសិទ្ធិជ្រកកោនផ្នែកនយោបាយនៅប្រទេសខ្មែរបាន ឬក៏ស្ថិតក្នុងឋានៈជាអ្នករកស៊ីជំនួញ ក្នុងនាមជាជនបរទេស មានលិខិតឆ្លងដែន ទិដ្ឋាការចេញ-ចូលត្រឹមត្រូវ ឬសុំច្បាប់អនុញ្ញាតិស្នាក់នៅប្រទេសខ្មែរស្របច្បាប់ ហើយត្រូវគោរពច្បាប់ផ្សេងៗគ្នា ដោយធ្វើការសម្របសម្រួល ជាមួយអាជ្ញាធរពាក់ព័ន្ធដោយអនុទ្យោមទៅតាមច្បាប់អន្តោប្រវេសន៍ នៃប្រទេសកម្ពុជា ហើយមិនអនុញ្ញាតិអោយជនណាម្នាក់រស់នៅខុសច្បាប់ដោយសេរី គ្មានការទទួលខុសត្រូវអ្វីនោះទេ។

**៨- ការអភិវឌ្ឍន៍វិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ប្រព័ន្ធហិរញ្ញវត្ថុ និងពន្ធដារ**

**៨.១ កសិកម្ម**

កសិកម្មជាកត្តាសំខាន់បំផុត នៃសេដ្ឋកិច្ចប្រទេសកម្ពុជា ដោយពលរដ្ឋខ្មែរ ៧៣% ជាកសិករ។ ដីកសិកម្មទាំងអស់ត្រូវមានការដាំដុះ ដាំអោយបានគ្រប់រដូវ ហើយដីដែលទំនេរត្រូវដកហូតជូនប្រជាពលរដ្ឋក្រីក្រ ដែលគ្មានដីដាំដុះ។ បង្កើនប្រព័ន្ធធារាសាស្ត្រ ទំនប់ ប្រឡាយ អាងទឹក ប្រព័ន្ធលូទឹកអោយបានទូទាំងប្រទេស ដើម្បីចែកចាយទឹកអោយបានដល់តំបន់ជនបទ ស្រុកស្រែចំការ និងតំបន់ដែលគ្មានទឹកសំរាប់ប្រើប្រាស់។

**៨.២ ពាណិជ្ជកម្ម**

បង្កើនវិនិយោគទុនទាំងក្នុង និងក្រៅប្រទេស ការពារមិនអោយមានការគៀបសង្កត់យកលុយពីអ្នកវិនិយោគទុនដោយនីតិវិធីច្បាប់។ រដ្ឋាភិបាលត្រូវបន្ថយពន្ធដារ និងតំលៃក្នុងការបើកក្រុមហ៊ុន និងមុខរបរទាំងអស់។ ដើម្បីបង្កើនការងារតាមរោងចក្រអោយបាន ៥០% នៃការងារទាំងអស់។ រដ្ឋាភិបាលនឹងជួយរកទីផ្សារ និងជួយផ្តល់មធ្យោបាយ ដើម្បីជួយសំរួលបញ្ហាទាំងអស់របស់អ្នកវិនិយោគទុន។

ទំនិញណាមិនបានផលិតក្នុងប្រទេសកម្ពុជា នឹងតម្រូវអោយបង់ពន្ធត្រឹម ២០% តែត្រូវបង្កើនពន្ធនាំចូល ១០០% ចំពោះទំនិញណាដែលផលិតបាននៅប្រទេសកម្ពុជា។

រដ្ឋាភិបាលត្រួតពិនិត្យ និងកំណត់តំលៃទំនិញ និងការប្រាក់ឥតមានការសមរម្យតាមប្រាក់បៀវត្សនិងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងមិនអោយមានការដាក់តំលៃខ្ពស់ ឬបន្ថោកតំលៃខុសប្រក្រតីដោយឥទ្ធិពលរបស់អ្នកមាន។ ធ្វើរោងចក្រ សហគ្រាស និងសិប្បកម្មច្នៃផលិតផលជារបស់កំប៉ុង កញ្ចប់ ប្រអប់កែវ ដប ។ល។ ដើម្បីនាំចេញទៅលក់នៅបរទេស ទាញអ្នកវិនិយោគក្រៅ និងក្នុងប្រទេស ដើម្បីបង្កើនអោយមានវារីអគ្គិសនី ផ្តល់ភ្លើងអោយបានគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាលមានភ្លើងប្រើប្រាស់ដូចនៅទីក្រុងដែរ។ ស្វែងរកកត្តាអនុគ្រោះពន្ធនាំចេញផលិតផលនានា និងផលិតផលវា

យនភ័ណ្ឌសំរាប់ប្រទេសនានា ជាពិសេសសហរដ្ឋអាមេរិក ដើម្បីបង្កើនការងារដល់ស្ត្រីអោយបានច្រើន ដែលឈានទៅលុបបំបាត់ចំនួនស្ត្រីបេស្យាចារក្នុងសង្គមខ្មែរ។

**៨.៣ ការកែតម្រូវប្រព័ន្ធហិរញ្ញវត្ថុ និងពន្ធដារ**

រៀបចំ កែប្រែថវិការជាតិ តាមរយៈការប្រមូលពន្ធាដារអោយបានត្រឹមត្រូវ ជៀសវាងការក្លែងបន្លំពីសំណាក់ភ្នាក់ងារគយ និងពន្ធដារ និងមន្ត្រីផ្សេងៗទៀតដែលពាកព័ន្ធ ដោយការប្រព្រឹត្តអំពើពុករលួយ។ សម្បត្តិធម្មជាតិដូចជារ៉ែ មាស ត្បូងថ្ម ត្បូង និងព្រៃឈើ ។ល។ រដ្ឋត្រូវកាន់កាប់កំរ៉ៃទាំងអស់បញ្ចូលក្នុងថវិការជាតិ។ ការបង់ពន្ធ ទ្រព្យសម្បត្តិ ដីធ្លីដូចមានចែងក្នុងចំណុច១១ នៃគោលនយោបាយនេះ ដោយធ្វើការពន្យល់ ណែនាំប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់អោយយល់ពីការបង់ពន្ធចូលថវិការជាតិ។

រូបិយវត្ថុបរទេសមិនអនុញ្ញាតិអោយចាយនៅលើទីផ្សារសាធារណៈក្នុងប្រទេសកម្ពុជាជាដាច់ខាត។ រូបិយវត្ថុបរទេសទាំងអស់ត្រូវប្តូរជាប្រាក់រៀលតាមអត្រាការប្រាក់ ដែលមានការកំណត់ត្រឹមត្រូវពីធនាគារជាតិ ហើយអ្នកប្រព្រឹត្តល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់។

រៀបចំអោយមានប្រព័ន្ធធនាគារគ្រប់ទីប្រជុំជន គ្រប់ឃុំ-សង្កាត់។ រាល់ការបង់ថ្លៃ ឬ ការផ្ទេរប្រាក់ជាមួយរដ្ឋត្រូវធ្វើតាមប្រព័ន្ធធនាគារ ដោយមិនទទួលលុយសុទ្ធទេ ដើម្បីការពារមិនអោយមានអំពើពុករលួយកេងប្រវ័ញ្ចលុយជាតិ។

**៩. ពង្រឹង និងពង្រីកវិស័យសិក្សាធិការ និងបណ្តុះបណ្តាលធនធានមនុស្ស**

ឧបត្ថម្ភលោកគ្រូ អ្នកគ្រូ និងផ្តល់ប្រាក់បៀវត្សសមរម្យ។ នៅសាលាបឋមសិក្សាត្រូវមានអាហារសំរាប់សិស្សានុសិស្ស ទឹកស្អាត ឧបករណ៍សិក្សា និងថ្នាក់រៀនគ្រប់គ្រាន់។ មិនត្រូវទុកក្មេងណាម្នាក់អោយនៅក្រៅសាលាជាដាច់ខាត។ បឋមសិក្សា និងមធ្យមសិក្សាត្រូវញុំាអាហារថ្ងៃត្រង់នៅសាលារៀន ស្នាក់នៅសាលាដល់ល្ងាចទើបត្រលប់មកផ្ទះដើម្បីទុកអោយមាតា បិតាប្រកបរបរចិញ្ចឹមជីវិតយុវជន ដែលមិនបានបន្តការសិក្សាត្រូវបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញ។ ផ្តល់អាហាររូបត្ថម្ភដល់និស្សិតក្រីក្រ ស្វែងរកអាហាររូបករណ៍ឧបត្ថម្ភជូននិស្សិតទៅសិក្សានៅបរទេស ក្នុងន័យបង្កើនចំណេះដឹង និងផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសផ្សេងៗ ដែលមានទំនាក់ទំនងល្អជាមួយប្រទេសកម្ពុជា។

**១០. បង្កើតអោយមាននាយកដ្ឋានសន្តិសុខសង្គម និងសុខមាលភាព**

រៀបបង្កើតអោយមាននាយកដ្ឋានសន្តិសុខសង្គម និងសុខមាលភាព ដើម្បីបើកអោយមានការចូលរួមសហការ រវាងអ្នកមាន ក្នុងគោលបំណងចូលរួមបន្ថយភាពក្រីក្រ បំបាត់អំពើពុករលួយ និងបំបាត់ចោរកម្មផ្សេងៗ ដែលធ្លាប់មាននៅក្នុងសង្គមខ្មែរ។ នាយកដ្ឋាននេះឧបត្ថម្ភដល់ ចាស់ជរា ជនពិការ កុមារកំព្រា ស្ត្រីមេម៉ាយ អ្នកក្រីក្រគ្មានការងារ គ្មានទីលំនៅ និងថែបំប៉នទារក កុមារ។ ចំណាយប្រាក់ព្យាបាលជូនអ្នកក្រីក្រទាំងអស់ជួយឧបត្ថម្ភជនរងគ្រោះធម្មជាតិ និងមហន្តរាយផ្សេងៗ។ ស្វែងរកការងារជូនប្រជាពលរដ្ឋជាពិសេសនិស្សិត ដែលទើបបញ្ចប់ដែលទើបបញ្ចប់ការសិក្សាថ្មី ប្រជាពលរដ្ឋទាំងអស់តម្រូវអោយមានអត្តលេខប្រចាំខ្លួន ដើម្បីទទួលផលប្រយោជន៍ពីនាយកដ្ឋាន សន្តិសុខសង្គម និងសុខមាលភាព។

**១១. ដោះស្រាយបញ្ហាដីធ្លីជូនប្រជាពលរដ្ឋ និងជួយសម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ**

សម្របសម្រួលជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីដោះស្រាយកែតម្រូវស៊ើបអង្កេត និងដោះស្រាយបញ្ហាដីធ្លីជូនប្រជាពលរដ្ឋក្រីក្រ ដែលត្រូវបានរឹបអូស ឬរំលោភបំពានដីធ្លី ពីសំណាក់ជនខិលខូចមួយចំនួន ដោយតម្រូវអោយមានការសងទូទាត់នូវតំលៃសមរម្យ ដើម្បីផ្លាស់ប្តូរទីលំនៅថ្មីអោយបានសមរម្យ។

**ការគ្រប់គ្រងទ្រព្យសម្បត្តិដីធ្លី មានបួនប្រការដូចតទៅ៖**

- តំបន់ដីធ្លីសំរាប់សាងសង់លំនៅដ្ឋាន និងដាំដុះជារបៀបគ្រួសារមិនត្រូវបង់ពន្ធទេ។
- តំបន់ដីធ្លីសំរាប់ធ្វើពាណិជ្ជកម្ម ការអភិវឌ្ឍន៍ និងសកម្មភាពធ្វើពាណិជ្ជកម្មផ្សេងៗ ត្រូវបង់ពន្ធ ៥% ជារៀងរាល់ឆ្នាំ។ បើសិនជាម្ចាស់កម្មសិទ្ធិមិនព្រមបង់ពន្ធរយៈពេល ២ឆ្នាំ កម្មសិទ្ធិដីនោះបែងចែងជូនប្រជាពលរដ្ឋក្រីក្រ ដែលត្រូវការធ្វើការដាំដុះ។
- តំបន់ដីធ្លីសំរាប់ធ្វើកសិកម្ម៖ អ្នកដែលមានដីធ្លីច្រើនជាង ១៨ហិកតា ត្រូវបង់ចូលរដ្ឋ ១.៩៩% ក្នុងមួយឆ្នាំ។ បើសិនជាមិនបង់ពន្ធក្នុងរយៈពេល ២ឆ្នាំត្រូវរឹបអូស។
- ដីសំរាប់ធ្វើឧស្សាហកម្ម ត្រូវបង់ពន្ធ ៨%ចូលថវិការជាតិ។

**១២. ការពារបរិស្ថាន និងសម្បត្តិធម្មជាតិ**

- **ព្រៃឈើ៖** ការកាប់បំផ្លាញព្រៃឈើត្រូវបានហាមឃាត់។ រដ្ឋាភិបាល នៃគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មានទិសដៅពង្រីកការដាំដុះព្រៃឈើលើផ្ទៃដីដែលត្រូវបានបំផ្លាញពីមុន។ គណបក្សនេះថែរក្សា និងអភិរក្សព្រៃឈើ។
- **សម្បត្តិវប្បធម៌ជាតិ៖** ថែរក្សា និងអភិរក្សបេតិកភណ្ឌជាតិ ដូចជា ប្រាង្គប្រាសាទ វត្ថុបុរាណនានាដែលមាននៅក្នុងប្រទេសកម្ពុជា។
- **ភ្នំ ៖** ភ្នំទាំងឡាយរួមទាំងសត្វព្រៃ និងអចលនទ្រព្យ ដែលមាននៅលើភ្នំត្រូវបានហាមឃាត់មិនអោយឈ្មួញធ្វើអាជីវកម្មរ៉ាយថ្ម ចាប់ និងសំលាប់សត្វព្រៃ ដែលជាផលប៉ះពាល់ដល់បរិស្ថានយ៉ាងធ្ងន់ធ្ងរ ហើយអាចប៉ះពាល់ដល់វត្ថុបុរាណ និងបាត់បង់ពូជសត្វព្រៃ ដែលមាននៅលើភ្នំនិមួយៗនោះ។
- **ទន្លេសាប និងសមុទ្រ ៖** គណបក្សមានការអភិរក្សតំបន់ជីវៈចំរុះ ដែលមិនអនុញ្ញាតិអោយមានឈ្មួះប៉ះពាល់ដល់បរិស្ថានជុំវិញ ឬក្នុងបឹងទន្លេសាប និងសមុទ្រ ដែលជាជម្រកត្រីសំរាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃ និងនាំចេញទៅលក់នៅទីផ្សារអន្តរជាតិ រដ្ឋាភិបាលបាន និងរៀបចំច្បាប់អោយបានតឹងរឹង ដោយហាមប្រាមការនេសាទគ្រប់ប្រភេទ ដែលអាចនាំអោយដល់ការផុតពូជត្រី និងការថយចុះទិន្នផលត្រី។
- **រ៉ែ៖** គណបក្ស គ.ស.រ.ប ការពារ និងអភិរក្សរ៉ែសំខាន់ៗទាំងនៅក្រោមដី ក្រោមភ្នំ សមុទ្រ និងក្នុងបឹងទន្លេសាប មិនអនុញ្ញាតិអោយឈ្មួញណាម្នាក់ធ្វើអាជីវកម្មក្នុងទ្រង់ទ្រាយណាមួយដែលនាំអោយខូចខាត និងបាត់បង់ទ្រព្យសម្បត្តិរ៉ែទាំងនោះឡើយ។ គ្រប់ទ្រព្យសម្បត្តិរ៉ែទាំងអស់ ជាមរតករួមរបស់ជាតិខ្មែរទាំងមូលមិនមែនជារបស់បុគ្គលណាម្នាក់ឡើយ។
  ដូច្នេះយើងត្រូវរួមគ្នាថែរក្សាសម្បត្តិទាំងនោះអោយបានគង់វង្ស ទុកជាកេរ្តិ៍ដំណែលជូនកូនចៅខ្មែរយើងជំនាន់ក្រោយ។
- **កាកសំណល់ នឹងជាតិពុល ៖** មិនអនុញ្ញាតិអោយឈ្មួញទុច្ចរិត យកព្រះរាជាណាចក្រកម្ពុជាជាកន្លែងផ្ទុកគ្រឿងកាកសំណល់ជាតិពុលឡើយ ដែលបង្ករអោយខូចបរិស្ថាន និងប៉ះពាល់ដល់

សុខភាពប្រជាពលរដ្ឋ។ គ្រប់រោងចក្រទាំងអស់ត្រូវគោរពតាមច្បាប់ការពារបរិស្ថានអោយបានត្រឹមត្រូវតាមក្បួនខ្នាត។

## ប្រឆាំងអំពើភេរវកម្មគ្រប់ប្រភេទ

មនុស្សសំដៅពុះពារ កសាងប្រទេសជានីតិរដ្ឋយ៉ាងពិតប្រាកដ ហើយប្រឆាំងរាល់សកម្មភាព ដែលបង្ករអោយមានភ្លើងសង្គ្រាម ប្រឆាំងដាច់ខាតនូវអំពើភេរវកម្មទាំងក្នុង និងក្រៅប្រទេស ហើយប្រឆាំងដាច់ខាតរាល់ការរំលោភលើរដ្ឋធម្មនុញ្ញ ប្រឆាំងការផ្តួលរំលំរដ្ឋាភិបាលដោយការប្រើអំពើហិង្សា ប្រើអាវុធដាច់ខាតការរំលោភសិទ្ធិប្រជាពលរដ្ឋ តាមគ្រប់រូបភាព។

ដោយអំពើពុករលួយរបស់មេដឹកនាំខ្មែរគ្រប់ជំនាន់ ដែលមានការជិះជាន់ បែងចែកវណ្ណៈ បណ្តាលអោយជាតិយើងជួបប្រទះនូវវិបត្តិម្តងហើយ ម្តងទៀត បែកបាក់សាមគ្គី បាត់បង់ឯកភាពជាតិ បង្ករអោយមានជំលោះ និងពង្វក់អោយខ្មែរកាប់សំលាប់ជាតិសាសន៍ឯង ហើយធ្វើអោយប្រទេសខ្មែរជួបប្រទះនូវហាយន្នភាពខ្ទេចខ្ទាំស្ទើរគ្មានសល់អ្វីទាំងអស់ ហើយបាត់បង់នូវកិត្យានុភាពជាតិ ដែលបណ្តាលអោយប្រទេសជាតិទាំងមូលបាត់បង់ពីផែនទីពិភពលោកទៀតផង។

ជាការពិតណាស់ យើងមិនអាចផ្លាស់ប្តូរអតីតកាលដ៏រុងរឿងបាន ដោយមានការបោះឆ្នោតគាំទ្រពីប្រជាពលរដ្ឋ ព្រោះមានតែប្រជាប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេស ម្ចាស់អំណាច ម្ចាស់ជោគវាសនារបស់ជាតិ ហើយប្រជាពលរដ្ឋមិនអាចក្លាយទៅជាទាសកររបស់អ្នកដឹកនាំបានឡើយ។

ដំណោះស្រាយដ៏ចំបងបំផុតរបស់គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គឺប្រគល់សិទ្ធិ និងអំណាចជូនប្រជាពលរដ្ឋខ្មែរ ដើម្បីលុបបំបាត់អំពើពុករលួយកាត់បន្ថយភាពក្រីក្រ ដោះស្រាយបញ្ហាជំលោះដីធ្លី កែប្រែប្រព័ន្ធទំរង់ច្បាប់ និងតុលាការងាយមានភាពឯករាជ្យប្រកបដោយយុត្តិធម៌ គ្មានអំពើហឹង្សា ដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ខុសច្បាប់ បណ្តុះបណ្តាលធនធានមនុស្ស និងចំណេះដឹងជូនប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប ដោះស្រាយបញ្ហាដោយសន្តិវិធី និងការអភិវឌ្ឍន៍លើគ្រប់វិស័យ។

ដូច្នេះ វាសនាប្រទេសជាតិយើង ត្រូវពឹងផ្អែកទៅលើជនរួមជាតិ ដែលជាម្ចាស់ឆ្នោត និងម្ចាស់កម្មសិទ្ធិ ហេតុដូច្នេះមុននឹងប្រគល់សន្លឹកឆ្នោតជូនគណបក្សណាមួយ ត្រូវពិចារណាបានច្បាស់លាស់ ដើម្បីរើសមេដឹកនាំជាតិយើង ប្រកបដោយគោលការណ៍ដឹកនាំតាមបែបប្រជាធិបតេយ្យមិនពុករលួយ គោរពច្បាប់ និងយកប្រជាពលរដ្ឋជាធំ។ ដែលជាការបោះឆ្នោត សុំសម្លេងគាំទ្រពីរាស្ត្រ គឺធ្វើឡើងពីជំហរប្រលងប្រណាំងសមត្ថភាព ក្នុងការដឹកនាំកសាងប្រទេសអោយបានរីកចំរើនលូតលាស់ សុខដុមរមនា មិនមែនធ្វើឡើងដោយប្រគួតប្រជែងយកស្លាប់រស់ដើម្បីអោយបានកាន់អំណាចនោះឡើយ។

គួរតែយល់ថា ការចែកអំណោយផ្សេងៗ នៅពេលឃោសនាបោះឆ្នោត គឺជារូបភាពប្រជាភិថុតិ នឹងជាការទិញសន្លឹកឆ្នោត ដែលបេក្ខជន និងគណបក្សនយោបាយគួរតែមានសេចក្តីអៀនខ្មាស់មិនគួរប្រព្រឹត្តសោះឡើយ។

គួរទុកខ្លួនជាអ្នកបំរើរាស្ត្រ ហើយរាស្ត្រជាម្ចាស់អំណាច បោះឆ្នោតជ្រើសរើសតាមបែបប្រជាធិបតេយ្យរៀងរាល់អាណត្តិ។ មិនគួរដាក់ខ្លួនជា (ម៉ែ ឪ រាស្ត្រឡើយ)។

គួរតែប្រូ្រតដៃគ្នាកសាងប្រទេសជាតិអោយបានច្រើនជាជាងអំណោយពេលរកល្បិចកិច្ចកល ដើម្បីក្តោបក្តាប់អំណាចតែមួយមុខនោះ។ ហើយកុំយកការបោះឆ្នោតជាល្បែងប្រជាធិបតេយ្យ ដើម្បីអំណាច ផលប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួក។

គួរតែយល់ថាជីវិតខ្លីណាស់ ពេលស្លាប់ទៅយកអ្វីទៅជាមួយមិនបានទេ មានតែកេរ្តិ៍ឈ្មោះទុកអោយសង្គមជាតិ និងក្រុមគ្រួសារ ហើយមិនត្រូវធ្វើខ្លួនជាមនុស្ស (ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ) ឡើយ។

## ប្រជារាស្ត្រ និងអ្នកបោះឆ្នោតទាំងឡាយ៖

គួរខិតខំពង្រីកការយល់ដឹង និងពង្រឹងស្មារតី (ខ្លួនទីពឹងខ្លួន) អោយបានរឹងមាំ។ អំណោយបន្តិចបន្តួចគ្រាន់តែជានុយ រឺជាការទិញទឹកចិត្តអោយយើងបោះឆ្នោតគាំទ្រពួកគេ និងគណបក្សគេតែប៉ុណ្ណោះ មិនអាចជួយរាស្ត្រ និងកសាងប្រទេសជាតិអោយរីកចំរើនរុងរឿង ជីវភាពធូធារនោះឡើយ។

គួរតែយល់ថា ជោគវាសនារបស់លោកអ្នក សំរេចចិត្តជ្រើសរើសខុសតែមួយជំហាន លោកអ្នកនឹងខកពេលអស់មួយអាណត្តិ ៤-៥ឆ្នាំ។

គួរពិនិត្យមើលឡើងវិញថា ពេលបោះឆ្នោតលើកមុនគណបក្ស និងបេក្ខជនបានសន្យាដូចម្តេចខ្លះ ដល់ពេលជាប់ឆ្នោតហើយ តើគេបានធ្វើសព្វគ្រប់ដូចសន្យាទេ តើជីវភាពលោកអ្នកមានភាពធូស្រាលជាងមុនឬទេ?

គួរតែជ្រើសរើសយកគណបក្ស ឬ បេក្ខជនណា ដែលចេះរក្សាព្រៃភ្នំក្រំថ្ម លតាវល្លិ ម្រឹគីម្រឹគា និងសមុទ្រ ទន្លេ ស្ទឹង បឹងបួ ព្រមទាំងមច្ឆាផងទាំងពួង សំរាប់អោយប្រជាពលរដ្ឋរស់រានមានជីវិតដោយសមរម្យ ថ្លៃថ្នូរ។

ពេលបោះឆ្នោតម្តងៗ គួរតែគិត ឬកំណត់ក្នុងចិត្តអោយបានច្បាស់ ថាតើលោកអ្នកចង់បានអ្វី ដូចជាចង់បានដីធ្លីសំរាប់ដាំដុះ ចង់បានទីផ្សារលក់ផលិតផល ចង់បានមន្ទីរពេទ្យល្អ សាលារៀនល្អ ស្ពានថ្នល់ល្អ ក្នុងភូមិ-ឃុំ ឬចង់បានប្រាក់ខែសមរម្យសំរាប់រស់នៅដោយថ្លៃថ្នូរ (បើជាអ្នករាជការ ឬ កម្មករ) ឬចង់មានការងារធ្វើក្រោយពីបញ្ចប់ការសិក្សារួច (បើជាសិស្សល្អ)។ ហើយបោះឆ្នោតអោយគណបក្ស ឬបេក្ខជនដែលសន្យាតាមការចង់បានរបស់លោកអ្នក។

## អំពើហឹង្សាលើស្ត្រីក្នុងសហគមន៍

## សេចក្តីផ្តើម

អំពើហឹង្សាបានផ្តល់នូវការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ យើងដឹងហើយថា បុគ្គលងាយរងគ្រោះជាងគេដោយសារអំពើហឹង្សាលើស្ត្រី និងកុមារ ជាភេទ ដែលមានភាពទន់ខ្សោយពុំមានកំលាំងគ្រប់គ្រាន់ក្នុងការតស៊ូ និងអំពើហឹង្សា។ តែស្ត្រីនេះហើយដែលមានតួនាទីយកចំណេះដឹងបានមកពីការរៀនសូត្រតាមរយៈឯកសារ (អំពើហឹង្សាទៅលើស្ត្រីភេទ និងច្បាប់) ផ្សព្វផ្សាយបន្តរទៅស្ត្រីម្នាក់ទៀត ដែលជាស្ត្រីមេផ្ទះម្នាក់ទៀតដែលជាស្ត្រីមេផ្ទះដូចគ្នា ព្រោះនៅទីក្រុងក្តី ជនបទក្តីច្រើននៅផ្ទះមើលថែទាំកូន ចៅ នៅផ្ទះសំបែងប៉ុណ្ណោះ ការបង្រៀនតគ្នានេះ បានកាត់ពីភាពយល់ដឹងដែលកើតមានឡើងនៅក្នុងសហគមន៍របស់ខ្លួន និងសហគមន៍នានាដែលមានឧបករណ៍ដូចជា (ក្នុងគ្រួសារមួយដែលកើតមានឡើងដោយសារតែប្តីវាយប្រពន្ធ ឬ ប្តីមានស្រីច្រើនមិនទទួលខុសត្រូវក្នុងបន្ទុកគ្រួសារ)។ ស្ត្រីត្រូវតែចេះរើបំរះពីការឈឺចាប់ទាំងផ្លូវកាយ ផ្លូវចិត្ត មិនត្រូវគិតតែខំខាំមាត់សង្កត់ចិត្ត ព្រោះខ្លាចខូចឈ្មោះ ឬអាស្រូវកេរ្តិ៍ តាមច្បាប់ស្ត្រីនោះទេ ពី ព្រោះច្បាប់ស្ត្រីនេះ គេបង្កើតឡើងសំរាប់អោយមនុស្សប្រុសមានអំណាច ធ្វើបាបស្រី តែបណ្ណោះ។ ហេតុនេះសមាជិក សហគន៍នីមួយៗជាពិសេសស្ត្រីយល់អោយច្បាស់ពីតំលៃរបស់ខ្លួនទោះបីកំលាំងកាយទន់ខ្សោយជាងបុរសមែនតែសត្តិបញ្ញារបស់ស្ត្រីមិនទន់ខ្សោយទេ ស្ត្រីអាចមានសត្តិបញ្ញាច្រើនជាងបុរសផង។ ទោះបីបុរសជាប្តីមានតួនាទីរកប្រាក់និងជាអ្នកចិញ្ចឹមគ្រួសារក៏ដោយ តែស្ត្រីជាភរិយាក៏ដោយ ក៏ភរិយាមានតួនាទីជាមេផ្ទះ ដែលមានភរកិច្ចក្នុងការបង្កើតនិងបីបាច់ថែរក្សាកូនចៅ ដែលមានទំហំធំជាងបុរសចេញរកប្រាក់ខាងក្រៅទៀតផង។ម៉្យាងទៀតវាជាភាពគួរអោយអាម៉ាសណាស់ពេលដែលបុរសជាប្តីបានប្រព្រឹត្តអំពើហិង្សា យ៉ាងឃោឃៅទៅលើស្ត្រីភេទហើយដែលបុរសដ៏ទៃទៀតមានដូចខ្លួនដែរ តែគេមិនធ្វើ ពីព្រោះគិតថានៅពេលដែលមានអំពើហិង្សានាំមកភាពអន្តរាយនិងកើតមានគ្រប់បែបយ៉ាង។

មានមតិជាងច្រើនបាននិយាយថាអំពើហិង្សាដែលកើតឡើងដោយសារមូលហេតុខាងលើនេះជាលេសរបស់ប្តីតំហូច មួយតែប៉ុណ្ណោះ។រាស់អំពើហិង្សាដែលមានដូចជា ហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រីភេទ ការរំលោភស្ត្រីភេទ ទាំងអស់នេះធ្វើអោយឈានទៅរកការអស់សង្ឃឹម ឈឺចាប់រហូតអស់មួយជីវិត បើសិនយើងបានយល់។ ការលំបាករបស់ប្រជាជនក្នុងសហគមន៍។

1- យកអំណាចជាធំ៖ គេមិនសូវយកចិត្តទុកដាក់ចំពោះប្រជាជនក្រីក្រទេ (គិតថាពីផលប្រយោជន៍ ផ្ទាស់ខ្លួន)
2- ប្រកាន់បក្សពួក៖ យកខ្សែស្រឡាយជាធំ:
    - ខ្វះប្រព័ន្ធអប់រំ៖ គ្មានការផ្សព្វផ្សាយចំណេះដឹងទូទៅ
    - សុខភាព អនាម័យ វិជ្ជាជីវៈផ្សេងៗអត់មានទាំងអស់
    - គ្មានសាលារៀន (នៅឆ្ងាយ) កុមាររៀនបានតិចតួច
    - ខ្វះជំរកផ្ទះសំបែងរយីករយាក (គ្មានលុយសង់)
    - ខ្វះការងារមកពីសមត្ថភាពចំណេះដឹងទាប (ក្រីក្រផុត)
    - ខ្វះអាហារ៖ គ្រួសារមានកូនច្រើននាក់ក្នុងបន្ទុក
    - ខ្វះថ្នាំសង្កូវ៖ គ្មានថវិកាគ្រប់គ្រាន់សំរាប់ព្យាបាល
    - គ្មានមណ្ឌលសុខភាព៖ (នៅឆ្ងាយ) អត្រាស្លាប់ច្រើនជាងគេពិសេសកុមារ និងស្ត្រី (មកពីមិនបានទទួលការអប់រំ )
    - ផ្លូវធ្វើចរាចរពីបាកបំផុត៖ មិនមានអ្នកណាជួយដោះស្រាយ
    - ខ្វះទឹកស្អាត៖គ្មានទឹកប្រើប្រាស់គ្រប់គ្រាន់ បណ្តាលអោយមានជំងឺមានដំបៅ រមាស់ស្បែកគ្រប់ប្រភេទ អប់រំ និង ផ្សព្វផ្សាយ ដល់មនុស្សជាតិនូវការ ការពារនិងកសាងធនធានធម្មជាតិនៅមូលដ្ឋាន។

ពាក្យថាបេតិកភណ្ឌជាតិ គឺសំដៅទៅលើទទ្រព្យសម្បត្តិ បេតិកភណ្ឌជាតិដែលបុព្វបុរសជូនតាយើងកសាងអោយយើងអស់រយៈកាលជាងពីរពាន់ឆ្នាំកន្លងមកនេះយើងទាំងអសើគ្នាជាខ្មែរត្រូវមានសិទ្ធិកាពារនិងចូលរួមការពារអោយបានអោយបានគង់វង្សបិតថេរតទៅទៀតហើយនិងកសាងសមិទ្ធិផលផ្សេងៗ

ដើម្បីអភិវឌ្ឍន៍ទុកជាមហាសម្បត្តិជាតិតទៅមុខទៀត។គោលដៅបំបាត់អំពើហិង្សា តើយើងធ្វើអ្វីបំបាត់អំពើហិង្សាក្នុងសង្គមជាតិ អំពើហិង្សាកើតមកពីមនុស្សអត់មានសីលធម៌ អត់មានគុណធម៌មិនគោរពច្បាប់ ថៃមទាំងអវិជ្ជាអោយចេះដឹងរួមនិងដើរតាមមាគាព្រះពុទ្ធជាម្ចាស់ ដូចជាធម៌រក្សាហិរិឧតបៈ សេចក្តីខ្មាស់បាប និងសេចក្តីខ្លាចបាបមិនបៀតបៀនអ្នកដទៃមិនធ្វើអោយអ្នកដទៃក្តៅក្រហាយដោយសារខ្លួនយើងមានព្រហ្មវិហារធម៌បួន មេត្តា ករុណា មុទិតា ឧបេក្ខា និងសីលប្រាំ បាណា អទិនា កាមេ មុសារ សុរា ហើយគោរពច្បាប់ជានិច្ចនេះហើយជាគំាបំបាត់អំពើហិង្សាក្នុងសង្គមគ្រួសារ និងសង្គមជាតិ ។បើបុគ្គលណាធ្វើតាមមាគ៌ាខាងលើនេះ គឺបានសេចក្តីសុខ បុគ្គលនិងគ្រួសារ បើ សង្គមជាតិ ធ្វើបានក៏បានសេចក្តីសុខនៅក្នុងសង្គមជាតិមាតុភូមិទាំងមូល។

រក្សាការពាររុក្ខជាតិ ធម្មជាតិ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ មានសិទ្ធដ៏ពិតប្រាដកក្នុងការការពារនិងចូលរួមការពារបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានគង់វង្ស និងស្អាតជានិច្ចដើម្បីសំរេចវត្ថុបំណងនេះ ត្រូវតែមណ្ដុះបណ្ដាល និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ នូវតំលៃរុក្ខជាតិ និងធម្មជាតិអោយគាត់យល់ច្បាស់ ដើម្បីជីវភាព សុខភាព សុខមាលភាពរបស់ប្រជាពលរដ្ឋ។

**រុក្ខា៖**

ពាក្យថា រុក្ខា គឺសំដៅទៅព្រៃឈើ ប្រទេសកម្ពុជាយើងបែងចែកជាបីតំបន់៖

1- តំបន់ខ្ពង់រាបៈសំដៅទៅលើតំបន់មានដីខ្ពស់និងភ្នំច្រើន។

2- តំបន់វាលរាបៈសំដៅទៅលើតំបន់ដែលមានដីស្រែចំការប្រជាពលរដ្ឋដែលមានព្រៃដុះ។

3- តំបន់វាលទំនាបៈ សំដៅទៅតំបន់សមុទ្រ ទន្លេចសាប និងបឹងបួរដែងទៀតនៅក្នុងទឹកដីប្រទេសខ្មែរដូចនេហទិសដៅគណបក្សយកចិត្តទុកដាក់ក្នុងការ

ការពារនិងចូលរួមការពារព្រៃឈើទាំងបីតំបន់នេះអោយគង់វង្សជាសម្បត្តិធម្មជាតិដ៏ពិតប្រាដក។

**មច្ឆានិងគង្គាៈ**

ពាក្យថាមច្ឆា គឺត្រីគង្គារ គឺទឹក នៅក្នុងប្រទេសខ្មែរយើងក៏ចែកចេញជាបីតំបននំដែរ តំបន់ខ្ពង់រាប តំបន់វាលរាប និងតំបន់វាលទំនាប ទិសដៅរបស់គណបក្សក្នុងការពារ និងករពារសម្បត្តិ មច្ឆានិងគង្គា អោយគង់វង្ស ដើម្បីបំបាត់ជនទុច្ចរិត បំផ្លិចបំផ្លាញជាតិ ដូចជាយកឧបករណ៍ខ្សែភ្លើង យកទៅឆក់ត្រី ក្នុងទឹក ដូចជាមង ឬគ៏អួនឥតក្រឡានិងឧបករណ៍ទាំងឡាយដែលធ្វើអោយប៉ល់ពាល់ដល់មច្ឆាជាតិ នេះជាកាតួកិច្ចរបស់ជាតិក្នុងការពារ និងចូលរួមការពារអោយបានគង់វង្ស។

**រក្សាការពារសត្វចតុតុបាតុ និងបក្សាបក្សីៈ**

ពាក្យថា ចតុបាត គឺសំដៅលើសត្វព្រៃមានជើងបួនដូចជាដំរី ទន្សោងខ្លាឃ្មុំ ខ្លាធំឈ្លូស ប្រើស រមាស គោព្រៃ ពាក្យថា បក្សាបក្សីសំដៅទៅលើសត្វញីឈ្មោល មានស្លាបដូចជាត្រដក់ ទុង ក្រសា ក្អែកទឹក គ្រាល ។ល។ និងសត្វទាំងឡាយណា ដែលមានច្បាប់ជាតិហាមមិនអោយបាញ់ រឺ ទាក់ ដាក់បង្គប់ ឬជាដើម ។ មានឆន្ទៈក្នុងការការពារដើម្បីបំបាត់ជនទុច្ចរិតបំផ្លាញជាតិអោយអស់ដើម្បីភាពគង់វង្សនៃសម្បត្តិ ជាតិដល់កុលបុត្តកុលធីតាខ្មែរជំនាន់ក្រោយទៅទៀត។ដើម្បីប្រឆាំងជួញដូរមនុស្សជាតិ ជាពិសេសភេទស្ត្រីៈ ជាបឋមតើយើងត្រូវធ្វើអ្វីខ្លះ ត្រូវមានច្បាប់ ហើយត្រូវអប់រំប្រជាពលរដ្ឋអោយស្គាល់ពីតំលៃសិទ្ធិមនុស្សម្នាក់ៗ មានតំលៃដូចគ្នា មានជីវិតដូចគ្នា ហើយក៏ចង់សើនៅមានសិទ្ធិសេរីភាព សមត្ថភាព យុត្តិធម៌ដូចមនុស្សទាំងអស់នៅលើផ្ទៃដីហើយមនុស្សយើងគ្រប់រូបមានស្អប់ខ្ពើមយ៉ាងខ្លាំងចំពោះអំពើជួញដូរភេទស្រីដែលជាខ្មែរយើង ជាតិយើងធ្លាប់មាន អរិយធម៌ វប្បធម៌ និងប្រពៃណី ដ៏ខ្ពង់ខ្ពស់យ៉ាងល្អប្រណិតដូចនេះហើយយើងត្រូវតែពួតដៃសាមគ្គីគ្នា រែករក មុខជនទុច្ចរិតយកមកផ្តន្ទាទោសទៅតាមផ្លូវច្បាប់ ទាំងអ្នករួមគំនិត និងអ្នកដៃដល់ អោយអស់ពីសង្គមជាតិយើងដើម្បីភាពថ្លៃថ្នូររុងរឿង និងតំលៃសុខដុមនាផង។

**ដើម្បីជីវភាព សុខភាព សុខមាលភាពៈ** ទៅដល់ចាស់ជរាគ្មានទីពឹង ស្ត្រីមេម៉ាយទីទាស់ក្រ និងកុមារកំព្រាគ្មានទីពឹងពាក់ស្នាក់អាស្រ័យ តោងយើងត្រូវធ្វើអ្វីខ្លះជូនពួកគាត់ ពាក្យថាជីវភាព គឺមានអាហារហូបចុកគ្រប់គ្រាន់មានសុខភាព មានថ្នាំសង្កូវ ទាំងបូរាណ មានប្រទេសនៅលើពិភពលោកយើងនេះដែលគេអភិវឌ្ឍន៍ដល់គំរិតទៅចាស់ជារា ទាំងជីវភាពសុខភាព សុខមាលភាព ដោយឡែកប្រទេសកំពុងអភិវឌ្ឍន៍រដ្ឋពុំមានលទ្ធិភាពធ្វើការនេះទាំងស្រុងទេមានតែយើងទាំងអស់គ្នាជាប្រជាពលរដ្ឋរួមព្រួតដៃសាមគ្គីគ្នាហើយសហាការ ជាមួយសមាគន៍ជាតិ និងសហគន៍ជាតិនិងអង្គការជាតិ និងអង្គការអន្តរជាតិរួមគ្នាយកចិត្តទុកដាក់ ជួយឧបត្ថមនូវជីវភាពសុខភាព និងសុខមាលភាពដល់ចាស់ជារាស្ត្រីមេម៉ាយទីទាស់ក្រជួយបង្កលក្ខណៈអោយមានអាជីព និងកុមារកំព្រាអោយមានការទីពឹងពាក់អាស្រ័យបានចូលរៀនដូចកុមារឯទៀតៗដើម្បីអភិវឌ្ឍន៍ធនធានមនុស្សអោយចាកផុតពីសេចក្តីល្ងង់ខ្លៅនេះជាទិសដៅដ៏ពិសិដ្ឋ និងអម្រែកពុនយ៉ាងធ្ងន់ធ្ងរសំរាប់ប្រទេសជាតិមាតុភូមិនៃយើងដាច់ខាត់ត្រូវតែធ្វើនិងចូលរួមធ្វើដើម្បីជីវិតមនុស្សជាតិ។

**ដើម្បីអភិវឌ្ឍន៍ធនធានមនុស្សៈ** មនុស្សមួយរូបៗ មានសារៈសំខាន់បំផុតត្រូវតែចេះគោរពច្បាប់ ហើយគោរពច្បាប់ក្នុងករណីកិច្ចដូចខាងលើនេះបើកវគ្គសិក្សានូវច្បាប់ជាតិ និងច្បាប់អន្តរជាតិ ជាច្បាប់សកល ដូចជារដ្ឋធម្មនុញ្ញ

ជាតិ រដ្ឋធម្មនុញ្ញជាតិសហជាតិកតិការសញ្ញា និងអនុសញ្ញាអន្តជាតិស្តីពីការគោពសិទ្ថិមនុស្ស លទ្ថិប្រជាធិបតេយ្យ សិទ្ធិនារី និងសិទ្ធិកុមារ។ល។ ជាពិសេសច្បាប់ទាំងឡាយណា ដែលប្រទេសកម្ពុជា ត្រូវយកមកគោព និងអនុវត្តន៍ ។ ដូចនេះហើយយើងត្រូវធ្វើសេចក្តីផ្សព្វផ្សាយ
ទៅដល់ប្រជាពលរដ្ឋអោយបានយល់ដឹងនិងចេះដឹងយ៉ាងច្បាស់អំពីច្បាប់ងាយស្រួយអភិវឌ្ឍន៍ធនធានមនុស្សដើម្បី ប្រឆាំងជនមិនគោរច្បាប់បំពានច្បាប់ រំលោភសិទ្ធិមនុស្ស បំពានលទ្ធិប្រជាធិតេយ្យអំណាចផ្តាច់ ការពុករលួយព្រៃផ្សៃអយុត្តិធម៌ក្នុងសង្គមដើម្បីភាពថ្លៃថ្នូររុងរឿងរបស់ប្រជាពលរដ្ឋខ្មែរគ្រប់ៗរូប លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិរបស់មនុស្សជាតិ៖មនុស្សគ្រប់ៗរូបទាំងអស់ត្រូវតែមានសិទ្ធិ សេរីភាព សន្តិភាព យុត្តិធម៌។

ពាក្យថា លទ្ធិប្រជាធិបតេយ្យ ពោលគឺ គោរពច្បាប់ មិនឃ្លាតអំពីច្បាប់ មិនបំពានច្បាប់ គោរពមតិភាគច្រើន។

ពាក្យថា សិទ្ធិមនុស្ស គឺមនុស្សសិទ្ធិសញ្ជាតិទាំងអស់ត្រូវតែមានសិទ្ធិធំៗទាំង៤៖

1- មនុស្សម្នាក់ៗត្រូវតែមានសិទ្ធិ មានជីវិត មានកិត្តិយស មានសិទ្ធិកសាងសង្គមគ្រួសារដោយស្របច្បាប់ មានសិទ្ធិរស់នៅឯប្រទេសក្រៅ ហើយក៏មានសិទ្ធិត្រលប់មកមាតុប្រទេសវិញដោយស្របច្បាប់ មានសិទ្ធបង្កើតគណបក្សនយោបាយ សហគមន៍ អង្គការ និងសហជីព ដោយស្របច្បាប់ មានសិទ្ធធ្វើនយោបាយ បំរើនយោបាយ មានសិទ្ធិឈរឈ្មោះអោយគេបោះឆ្នោត និងទៅបោះឆ្នោតអោយតំណាងរបស់ខ្លួនដែលខ្លួនពេញចិត្ត។
2- មនុស្សគ្រប់ៗរូបមានសេរីភាព ខាងបញ្ចេញមតិដោយសេរី ចូលរួមប្រជុំដោយសន្តិវិធី សេរីភាពក្នុងជំនឿសាសនាពេញទី សេរីភាពដើរហើរឆ្វាយជិតដោយសេរី។
3- មនុស្សគ្រប់ៗរូប ត្រូវមានភាពស្មើរគ្នាចំពោះមុខច្បាប់ មិនថាអ្នកធំ ឬអ្នកតូច មិនថាអ្នកមានអំណាច ឬអត់អំណាច អ្នកមាន ឬអ្នកក្រ បើប្រព្រឹត្តិខុសពីច្បាប់ ត្រូវផ្តន្ទាទោសចំពោះអ្នកខុសច្បាប់ ហើយអ្នកដែលមិនបានខុសច្បាប់ត្រូវតែការពារ នោះទើបសមភាពមានស្មើរគ្នាចំពោះមុខច្បាប់។
4- ធ្វើអោយមានយុត្តិធម៌នៅក្នុងសង្គមជាតិ លទ្ធិប្រជាធិបតេយ្យ ជាស្នូលនៃការការពារសិទ្ធិ សេរីភាព និងសមភាពមនុស្សម្នាក់ៗក្នុងសង្គមប្រជាធិបតេយ្យ បើមានលក្ខណៈទាំងបួនយ៉ាងខាងលើនេះហើយ យុត្តិធម៌ក្នុងសង្គមជាតិ នឹងកើតមានហើយ តែផ្ទុយទៅវិញ មនុស្សគ្រប់រូបទាំងអស់ បើមានសិទ្ធិ សេរីភាព សមភាព មិនគ្រប់គ្រាន់តាមផ្លូវច្បាប់ទេនោះ យុត្តិធម៌មិនមានឡើយ។